book2:Layout 1 11/11/2010 3:00 PM Page 1

# ស្តង់ដារទឹកឃ្មុំព្រៃកម្ពុជា




សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា

book2:Layout 1 11/11/2010 3:00 PM Page 2




**ទំនាក់ទំនង ស.ច.អ.យ**

តាមរយៈអង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អនុផលព្រៃឈើ (NTFP-EP) ផ្ទះលេខ 10E0
ផ្លូវលេខ ៤២០ សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ: +៨៥៥ (0)២៣ ៧២៧ ៤0៧
Email: ntfp_epc@online.com.kh /Website: www.ntfp.org
: ntfp_marketing@online.com.kh

NTFP Exchange Programme for South & Southeast Asia

CBHE

CAMBODIA NTFP WORKING GROUP

book2:Layout 1  11/11/2010  3:00 PM  Page 4

# សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា

# ស្តង់ដារទឹកឃ្មុំព្រៃកម្ពុជា

## មិថុនា ២០១០

book2:Layout 1  11/11/2010  3:00 PM  Page 5

**ស្តង់ដារទឹកឃ្មុំព្រៃកម្ពុជា**


មិថុនា ២០១០

សៀវភៅស្តង់ដារទឹកឃ្មុំព្រៃកម្ពុជាត្រូវបានរៀបចំដោយ :

គណកម្មការ សមាជិកសហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជាព្រមទាំងអង្គការដៃគូរ

**រូបភាពដោយ** : អាន រស្មី

**រចនាដោយ** : ខ្មែរឌីហ្សាញគ្រុប (Khmer Design Group)



**រក្សាសិទ្ធិ** : ផ្នែកណាមួយក៏ដោយនៅក្នុងសៀវភៅស្តង់ដារនេះមិនត្រូវយកមកផលិតឡើងវិញ រឺ ប្រើប្រាស់ក្នុងរូបភាពណាមួយ ដោយពុំមានការអនុញ្ញាតិឡើយ ។



បោះពុម្ពនៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



**ដៃគូគាំទ្រ :**

សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា សូមថ្លែងអំណរគុណដល់អ្នកចូលរួមគាំទ្រដែលមានរាយនាមដូចខាងក្រោមៈ

អង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អនុផលព្រៃឈើអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ( NTFP-EP for South and Southeast Asia)

អង្គការមូលនិធិដើម្បីអភិរក្សធម្មជាតិនៅកម្ពុជា (WWF Cambodia)

អង្គការអ៊ុកស្វាម ហុង កុង (Oxfam Hong Kong)

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)

អង្គការព្រៃឈើតំបន់ត្រូពិចអន្តរជាតិ (ITTO)

សហគ្រាសសេដាក (SKC)

IUCN NL Ecosystem Grants Programme (EGP)

ARUN LLC

book2:Layout 1 11/11/2010 3:29 PM Page 6




# មាតិកា

ពត៌មានសង្ខេប សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា ............................១
សេចក្តីណែនាំអំពីសៀវភៅស្តង់ដារឃ្មុំព្រៃកម្ពុជា................................................៣
គោលការណ៍សំខាន់ៗនៅក្នុងដំណើរការប្រមូលទឹកឃ្មុំព្រៃរហូតដល់ទីផ្សារ.......................៥
ការគ្រប់គ្រងដោយមានការទទួលខុសត្រូវ និងនិរន្តរភាព.........................................៦
គុណភាពផលិតផល និងការថែរក្សាប្រព័ន្ធត្រួតពិនិត្យគុណភាពផលិតផល........................៩
ការកសាងសមត្ថភាព និងទំនាក់ទំនង.......................................................១៤
ការបែងចែកផលប្រយោជន៍...............................................................១៦


29
730
731
732
កម្ពុជាសំបូរធនធានព្រៃឈើដែលជាជំរក
ដ៏ពិសេសសម្រាប់សត្វឃ្មុំ និងសត្វព្រៃ



# ព័ត៌មានសង្ខេប សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា

សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជាបានបង្កើតឡើងនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១០ និងមានអ្នកចូលរួមសរុប ៥៨ នាក់ ដែលក្នុងនោះមានប្រតិភូតំណាងសហគ្រាសអ្នកប្រមូលទឹកឃ្មុំនៅតាមមូលដ្ឋានចំនួន៤០រូប តំណាងអង្គការដែលគាំទ្រដល់សហគ្រាសចំនួន ១២រូប តំណាងអាជ្ញាធរមូលដ្ឋានចំនួន ០២រូប ( ក្រុមប្រឹក្សាឃុំចំនួន ០២រូបមកពីខេត្តកោះកុង និងខេត្តព្រះវិហារ) ជំនួយការរៀបចំមកពី NTFP-EP ចំនួន ០២រូប អ្នកធ្វើកំណត់ហេតុ ០១រូប និងអ្នកសម្របសម្រួល ០១ រូបរបស់អង្គការ CIRD ។ តំណាងសហគ្រាសអ្នកប្រមូលទឹកឃ្មុំទាំងនោះមកពីខេត្តចំនួន០៦រួមមាន ខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ព្រះវិហារ កោះកុង និងស្ទឹងត្រែង ។

ទីតាំងនៃសមាជិកសហព័ន្ធ សហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា




សហព័ន្ធមានឈ្មោះ **" សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា "** សរសេរជាអក្សរកាត់ថា **"ស.ប.អ.ឃ"** និងសរសេរជាភាសារអង់គ្លេសថា "Cambodian Federation for Bee Conservation and Community based Wild Honey Enterprises" អក្សរកាត់ជាភាសាអង់គ្លេស "CBHE" ។

ទីតាំងទីស្នាក់ការនៅ ផ្ទះលេខ 10 Eo ផ្លូវលេខ 420 សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ( ប្រើប្រាស់ការិយាល័យរបស់ NTFP-EP នៅភ្នំពេញជាបណ្តោះអាសន្ន ) ។

## គោលបំណង និងបេសកកម្ម

- បង្កើតអោយមានស្តង់ដាររួមមួយសម្រាប់ផលិតផលទឹកឃ្មុំព្រៃកម្ពុជា
- ស្វែងរកទីផ្សារលក់ និងបង្កើននូវតម្លៃផលិតផលទឹកឃ្មុំព្រៃកម្ពុជា
- ចូលរួមចំណែកក្នុងការអភិរក្សធនធានព្រៃឈើ និងអនុផលព្រៃឈើ
- លើកកម្ពស់កម្រិតជីវភាពរបស់សហគមន៍តាមរយៈការពង្រឹងអាជីវកម្មទឹកឃ្មុំព្រៃកម្ពុជា

ដើម្បីសម្រេចគោលបំណងនេះ **ស.ប.អ.ឃ** មានបេសកកម្មរួមចំណែកអភិរក្សធនធានព្រៃឈើ និងលើកកម្ពស់ជីវភាពសហគមន៍តាមរយៈការប្រមូលទឹកឃ្មុំប្រកបដោយនិរន្តរភាពការបង្កើន និងផ្សព្វផ្សាយគុណភាពផលិតផលឃ្មុំព្រៃ ។

book2:Layout 1 11/11/2010 3:33 PM Page 9





# សេចក្តីណែនាំអំពីសៀវភៅស្តង់ដារឃ្មុំព្រៃកម្ពុជា

ការប្រមូលទឹកឃ្មុំព្រៃ គឺជាប្រពៃណីដ៏យូរលង់ណាស់មកហើយសម្រាប់អ្នកប្រមូលទឹកឃ្មុំដែលរស់នៅក្នុងសហគមន៍ ដែលពឹងអាស្រ័យលើព្រៃឈើនៅក្នុងប្រទេសកម្ពុជា ជាពិសេសសហគមន៍ជនជាតិដើមភាគតិច ។ តាមទំនៀមទំលាប់ ទឹកឃ្មុំដែលប្រមូលបានត្រូវបានគេប្រើប្រាស់ជាឱសថ និងអាហារនៅតាមផ្ទះ ។ ការធ្វើអាជីវកម្មទឹកឃ្មុំបានធ្វើឱ្យវិធីសាស្រ្តនៃការប្រមូលទឹកឃ្មុំប្រកបដោយនិរន្តរភាពមានការប្រែប្រួល ហើយនៅក្នុងករណីខ្លះគឺមិនមានការអនុវត្តដោយសុច្ចរិតទេនៅលើចំនុចមួយចំនួន ( ឧទាហរណ៍ ការលក់ទឹកឃ្មុំក្លែងក្លាយ) ដែលកត្តាទាំងនេះបានរួមចំណែកធ្វើឱ្យមានការមន្ទិលសង្ស័យលើគុណភាពទឹកឃ្មុំព្រៃកម្ពុជាដែលមានលក់នៅលើទីផ្សារ ។ ការធ្វើឱ្យទឹកឃ្មុំមានគុណភាព និងការកសាងទំនុកចិត្តដល់អ្នកប្រើប្រាស់ គឺជាកត្តាមួយចាំបាច់ដើម្បីចូលទៅកាន់ទីផ្សារ និងធ្វើឱ្យមានស្ថេរភាពទីផ្សារ ។

ការប្រមូលទឹកឃ្មុំសម្រាប់ជីវភាពរស់នៅកំពុងស្ថិតនៅក្រោមការគម្រាមកំហែង ពីព្រោះឃ្មុំព្រៃកំពុងត្រូវបានគម្រាមកំហែងដោយសារតែការបាត់បង់ និងការថយចុះគុណភាពព្រៃឈើដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ជំរក និងប្រភពចំណីអាហារសំខាន់ៗរបស់ឃ្មុំ ។ ដូចគ្នានេះដែរការប្រែប្រួលអាកាសធាតុដូចជា ភ្លៀងច្រើនពេក រឺភាពរាំងស្ងួតបានធ្វើឱ្យប៉ះពាល់ដល់សុខភាព និងការបន្តពូជរបស់ឃ្មុំ ។ ការផ្សារភ្ជាប់ដ៏មានសារសំខាន់នេះបានបង្ហាញអំពីសារប្រយោជន៍នៃការការពារព្រៃឈើ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព ។

ស្តង់ដារនេះបានបង្កើតឡើងចេញពីចំណេះដឹង និងជំនាញតាមបែបប្រពៃណីដែលមានស្រាប់ក្នុងការប្រមូលទឹកឃ្មុំ ការបង្កើនតម្លៃនៅក្នុងប្រទេសកម្ពុជា និងរួមជាមួយបទពិសោធន៍របស់សហគមន៍ផ្សេងៗទៀតនៅក្នុងប្រទេសមួយចំនួន ។ ស្តង់ដារនេះបានបង្កើតឡើងតាមរយៈការប្រមូលផ្តុំនូវបច្ចេកទេសប្រមូលល្អៗរបស់សហគមន៍មួយចំនួនដែលបានចែករំលែកតាមរយៈការរៀបចំទស្សនៈកិច្ចសិក្សា សកម្មភាពបង្កើនសមត្ថភាព និងការរៀនសូត្រពីធនធានមនុស្សមួយចំនួន ។ ដូចនេះស្តង់ដារទឹកឃ្មុំដែលបានបង្កើតឡើងនឹងអាចធ្វើឱ្យសមាជិក និងសមាគមដែលជាសមាជិកនៃសហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា **(CBHE)** មានភាពងាយស្រួលក្នុងការអនុវត្ត ។

បេសកកម្មរបស់សហពន្ធ័ សហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា គឺចូលរួមចំណែកការពារធនធានព្រៃឈើ និងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍តាមរយៈការប្រមូលទឹកឃ្មុំព្រៃប្រកបដោយនិរន្តរភាព និងបង្កើនការផ្សព្វផ្សាយអំពីគុណភាពផលិតផលទឹកឃ្មុំព្រៃ ។

book2:Layout 1 11/11/2010 3:37 PM Page 11

# សហគមន៍

# និងធនធានឃ្មុំក្នុងព្រៃសហគមន៍យើង





# គោលការណ៍សំខាន់ៗនៅក្នុងដំណើរការប្រមូលទឹកឃ្មុំព្រៃ រហូតដល់ទីផ្សារ



**១**
ការគ្រប់គ្រងដោយ
មានការទទួលខុសត្រូវ
និងនិរន្តរភាព

**២**
គុណភាពផលិតផល
និងការថែរក្សាប្រព័ន្ធ
ត្រួតពិនិត្យគុណភាព
ផលិតផល





**៣**
ការកសាងសមត្ថភាព
និងទំនាក់ទំនង

**៤**
ការបែងចែក
ផលប្រយោជន៍



## គោលការណ៍ទាំងនេះត្រូវអនុវត្តដោយសមាជិក និង សមាគមក្នុងរូបភាពជាស្តង់ដារសម្រាប់ឃ្មុំព្រៃដូចខាងក្រោមៈ

book2:Layout 1 11/11/2010 3:50 PM Page 13



# ១. ការគ្រប់គ្រងដោយមានការទទួលខុសត្រូវ និងនិរន្តរភាព

- ទឹកឃ្មុំព្រៃគឺត្រូវប្រមូលចេញពីព្រៃធម្មជាតិដូចជាព្រៃកោងកាង និងតំបន់ដីសើមដែលមាននៅក្នុងតំបន់ព្រៃការពារ រឺ ព្រៃសហគមន៍ លើកលែងចំការកសិកម្មមួយចំនួន ដូចជាចំការកៅស៊ូ ចំការស្វាយចន្ទី និងចំការដំណាំផ្សេងៗទៀត ។



- ត្រូវគោរពប្រពៃណីព្រៃឈើរបស់ជនជាតិដើមភាគតិច និងក្បួនតម្រាផ្សេងៗរបស់ពួកគេ
- ត្រូវគោរពភាពជាម្ចាស់តាមបែបប្រពៃណីនៃដើមឈើដែលឃ្មុំធ្វើសំបុក និងធ្វើបង្គង



- ប្រតិបត្តិតាមរដូវកាលនៃការប្រមូលទឹកឃ្មុំ ។
- ការប្រមូលទឹកឃ្មុំនៅរដូវប្រាំងអាចចាប់ផ្ដើមពី ខែមីនា ដល់ខែឧសភា ហើយរដូវវស្សាអាចចាប់ផ្ដើមប្រមូលពី ខែមិថុនា ដល់ខែកញ្ញា ។



- ប្រមូលតែផ្លិតឃ្មុំណាដែលចាស់ រឺ ទឹកឃ្មុំចាស់នៅពេលដែលកោសិកាក្រមួនឃ្មុំបិទជិត ហើយក្បាលទឹកឡើងក្រាស ។
- ប្រមូលយកតែផ្លិតឃ្មុំ ហើយរក្សាទុកនូវកូនឃ្មុំ
- ប្រមូលយកតែផ្នែកខ្លះនៃផ្លិតឃ្មុំ ហើយមិនត្រូវប្រមូលយកផ្លិតឃ្មុំទាំងមូលនោះទេ



- ប្រើផ្សែង មិនត្រូវប្រើភ្លើង រឺ ថ្នាំសម្លាប់សត្វចង្រៃនោះទេ ក្នុងពេលប្រមូលទឹកឃ្មុំ
- ដើម្បីឱ្យមានសុវត្ថិភាពត្រូវប្រើប្រាស់សំលៀកបំពាក់ការពារ (ស្រោមដៃវែង មួកការពារមុខ សំលៀកបំពាក់ក្រាស់ៗ និងខោជើងវែង) ។ ប្រើប្រាស់ខ្សែរវែងសម្រាប់ចងរឹតជុំផ្សែងភ្លើង ។



book2:Layout 1 11/11/2010 3:51 PM Page 14

ជៀសវាងការប្រមូលទឹកឃ្មុំពេលយប់

ត្រូវអនុវត្តតាមច្បាប់នានាដែលមានស្រាប់ (ច្បាប់ការពារព្រៃឈើ ច្បាប់ការពាតំបន់ការពារធម្មជាតិ និងច្បាប់ការពារសហគមន៍ព្រៃឈើ) និងត្រូវតាមដានទៅលើការអនុវត្តច្បាប់ទាំងនោះដូចជា:



- មិនត្រូវបរបាញ់សត្វព្រៃ
- មិនត្រូវដុតព្រៃ
- មិនត្រូវចូលទៅប្រមូលអនុផលព្រៃឈើនៅក្នុងតំបន់ស្នូលរបស់សហគមន៍ព្រៃឈើ
- មិនត្រូវយកភ្លើងចូលទៅក្នុងព្រៃ
- មិនត្រូវកាប់បំផ្លាញដើមឈើ



ប្រើប្រាស់វិធីតាមដានដោយមានការចូលរួមដូចជា:

- ធ្វើផែនទីតំបន់ដែលត្រូវប្រមូលឃ្មុំ
- បោះស្លាកដើមឈើ រឺបង្គងដែលឃ្មុំធ្វើសំបុក
- កត់ត្រាពតិមានអំពីការប្រមូលទឹកឃ្មុំ
- ចុះល្បាត និងតាមដានព្រៃឱ្យបានទៀងទាត់



ត្រូវប្រមូលពតិមានមួយចំនួនសម្រាប់ធ្វើផែនការ និងតាមដានការប្រើប្រាស់ធនធានប្រចាំឆ្នាំដូចជា:

- ទីតាំង និងទំហំផ្ទៃដី តំបន់ត្រូវប្រមូល (មុនពេល កំឡុងពេល និងក្រោយរដូវកាលប្រមូល)
- ប្រភពចំណីអាហាររបស់ឃ្មុំ (ប្រភេទរុក្ខជាតិ)
- អ្នកប្រមូលទឹកឃ្មុំ សមាជិកក្រុមអ្នកប្រមូលទឹកឃ្មុំ និងបរិមាណនៃការប្រមូលប្រចាំឆ្នាំ
- ការផ្លាស់ប្តូរទាំងឡាយណាដែលអាចសង្កេតមើលឃើញនៅក្នុងតំបន់ប្រមូលទឹកឃ្មុំ ។



# ផ្កាព្រៃជាប្រភពអាហារសម្រាប់សត្វឃ្មុំ



book2:Layout 1 11/11/2010 3:59 PM Page 16



# ២. គុណភាពផលិតផល និងការថែរក្សាប្រព័ន្ធត្រួតពិនិត្យគុណភាពផលិតផល

រក្សាភាពស្អាតឱ្យមានកម្រិតខ្ពស់ និងអនាម័យខ្លួនប្រាណក្នុងកំឡុងពេលប្រមូលទឹកឃ្មុំ និងចាប់កាន់ទឹកឃ្មុំគ្រប់ពេលវេលាទាំងអស់ ។ ការត្រួតពិនិត្យគុណភាពត្រូវធ្វើឡើងនៅតំណាក់កាលផ្សេងៗគ្នា នៅពេលប្រើទឹកឃ្មុំដោយគិតចាប់ពី



ក- ការប្រមូលទឹកឃ្មុំ

ខ- ការកែច្នៃនៅដំណាក់កាលដំបូង (ការត្រៀមទិញលក់)

គ- ការទិញលក់

ឃ-ការកែច្នៃ ការស្តុកទុក ការវេចខ្ចប់ និងការទទួល និងបែងចែកទឹកឃ្មុំ ។

### ក) ការប្រមូលទឹកឃ្មុំ:

- ប្រមូលតែទឹកឃ្មុំណាដែលចាស់មិនត្រូវលាយទឹកឃ្មុំបញ្ចូលគ្នានោះទេ (ឃ្មុំចាស់ និងឃ្មុំថ្មី ប្រភពតំបន់ដែលខុសគ្នា) ។
- យកផ្លិតឃ្មុំដែលប្រមូលបានទៅសំអាតនៅកន្លែងដែលស្អាតនៅក្នុងព្រៃ ។ ប្រើប្រាស់ធុងដែលស្ងួតហើយស្អាតដើម្បីដាក់ផ្លិតឃ្មុំ ។
- ត្រូវយកឃ្មុំដែលងាប់ និងកំទេចកំទីផ្សេងៗដែលនៅជាប់នឹងផ្លិតឃ្មុំ រឺធុងទឹកឃ្មុំចេញដោយប្រុងប្រយត្ន័ ។



### ខ) ការកែច្នៃនៅដំណាក់កាលដំបូង( ការត្រៀមទិញលក់ )

- ត្រូវរក្សាទុកចំណែកលំអងផ្កាដោយឡែកពីទឹកឃ្មុំ
- មិនត្រូវច្របាច់ទឹកឃ្មុំដោយប្រើដៃទេ
- ត្រូវចៀរក្បាលទឹកឃ្មុំតាមបណ្តោយក្បាលទឹកឃ្មុំ ដើម្បីឱ្យទឹកឃ្មុំស្រក់ចេញមកដោយខ្លួនឯងមិនចាំបាច់ច្របាច់ ។ យើងត្រូវកាត់ក្បាលទឹកជាបំណែកតូចៗ ដើម្បីឱ្យទឹកឃ្មុំហូរចេញពីក្បាលទឹកដល់កម្រិត



អតិបរិមា ។ ត្រូវរឹតក្បាលទឹកឃ្មុំដែលបានកាត់ជាចំណែកតូចៗនៅក្នុងក្រណាត់ដែលស្អាតដើម្បីសម្រក់ទឹកឃ្មុំឱ្យអស់ពីក្បាលទឹក ។



- ប្រើស្រោមដៃមានគុណភាពល្អ (ប្រភេទស្រោមដៃប្រើសម្រាប់ចាប់កាន់ចំណីអាហារ) ដែលត្រូវបានគេប្រើដើម្បីចាប់កាន់ចំណីអាហារសម្រាប់ចាប់កាន់ផ្លិតឃ្មុំ ។ សំអាតស្បែអោយស្អាតសម្រាប់សម្រក់ទឹកឃ្មុំ និងប្រើកាំបិតឬស្សី រឺឈើដើម្បីកាត់ផ្លិតឃ្មុំតូចៗ ។



- ធុង និងសំភារៈផ្សេងៗ ដែលប្រើប្រាស់សម្រាប់ប្រមូល និងទុកដាក់ទឹកឃ្មុំត្រូវតែសំអាត និងហាលឱ្យស្ងួត ។

**គ) ការទទួលទិញទឹកឃ្មុំ :**

ទឹកឃ្មុំដែលប្រមូលបាន ត្រូវទទួលទិញដោយសហគ្រាសសហគមន៍មួយដែលគ្រប់គ្រងក្រុមអ្នកប្រមូលទឹកឃ្មុំព្រៃ ។ អ្នកដែលត្រូវបានជ្រើសរើសសម្រាប់ធ្វើការត្រួតពិនិត្យ ត្រូវតែត្រួតពិនិត្យគុណភាពទៅតាមការកំណត់មួយចំនួនដូចជាកម្រិតជាតិទឹកការលាយចូលគ្នា និងភាពសុទ្ធ ។ ឯកសារផ្សេងៗត្រូវតែរៀបចំសម្រាប់តាមដាននៅថ្ងៃអនាគត ។



**ការត្រួតពិនិត្យទឹកឃ្មុំ:**

- **ពណ៌របស់ទឹកឃ្មុំ :** ពណ៌មាសទៅពណ៌ក្រហមក្រម៉ៅ
- **រសជាតិ និងក្លិនៈ** មានរសជាតិផ្អែម និងមានក្លិនក្រអូបដូចផ្កាព្រៃ
- **កម្រិតជាតិទឹកអតិបរិមា :** ២៤ % (ចំណាំៈត្រូវប្រើប្រដាប់ស្ទង់ទឹកឃ្មុំសម្រាប់វាស់វែង)





- **ធុងទឹកឃ្មុំ** មិនត្រូវមានលាយជាមួយឃ្មុំដែលងាប់ និងកំទេចកំទីផ្សេងៗទៀតនោះទេ ។ ដើម្បីឱ្យការរៀបចំឯកសារ និងការតាមដានមានដំណើរការបានល្អត្រូវតែធ្វើការកត់ត្រាឱ្យបានលំអិតពីការទទួលទិញទឹកឃ្មុំដូចជា ឈ្មោះអ្នកប្រមូល រឺឈ្មោះក្រុម ឈ្មោះតំបន់



book2:Layout 1  11/11/2010  4:02 PM  Page 18

ដែលបានប្រមូល (លេខកូដបើសិនជាមាន) បរិមាណទឹកឃ្មុំដែលបានទទួលទិញ ។ ធុងទឹកឃ្មុំនិមួយៗត្រូវតែមានពតិមានមួយចំនួនដូចជា:



- ឈ្មោះផលិតផល និងឈ្មោះម្ចាស់ផលិតផល
- បរិមាណប្រមូល និងទទួលទិញទឹកឃ្មុំ
- កម្រិតជាតិទឹក និងចំណាត់ថ្នាក់ទឹកឃ្មុំ (ចំណាត់ថ្នាក់ត្រូវបានគេផ្តល់ឱ្យបន្ទាប់ពីធ្វើការត្រួតពិនិត្យរួច) ។

### ឃ) ការកែច្នៃ (ការច្រោះ និងចាក់ទឹកឃ្មុំ)

ការកែច្នៃតាមរយៈការច្រោះ និងរក្សាទុកជួយធ្វើឱ្យទឹកឃ្មុំរក្សាបាននូវគុណភាព រសជាតិ និងពណ៌ធម្មជាតិរបស់វា ។ ការច្រោះ និងការចាក់ទឹកឃ្មុំត្រូវតែធ្វើឱ្យបានឆាប់បំផុត បន្ទាប់ពីការទិញទឹកឃ្មុំ រឺយ៉ាងយូរ ១០ថ្ងៃបន្ទាប់ពីប្រមូល ។ ការកែច្នៃបន្ថែមនឹងត្រូវបានគេធ្វើម្តងទៀតនៅមុនពេលវេចខ្ចប់លក់ចុងក្រោយ ដើម្បីកាត់បន្ថយជាតិទឹក ។



- ការកែច្នៃត្រូវតែធ្វើនៅក្នុងបន្ទប់ដែលមានអនាម័យ គ្មានធូលី ស្ងួតល្អ និងនៅក្នុងបន្ទប់ដែលអាចគ្រប់គ្រងសីតុណ្ហភាពបាន ។ ជាការល្អត្រូវកែច្នៃនៅក្នុងបន្ទប់ ដែលមានទំហំតូចបំផុតត្រឹម ៣ម x ៤ម និងមានទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ។ អង្កេតមើលអនាម័យឱ្យបានសមរម្យក្នុងពេលកំពុងកែច្នៃ ។ ត្រូវពាក់ស្រោមដៃ និងម៉ាសការពារ ។
- មិនត្រូវលាយទឹកឃ្មុំបញ្ចូលគ្នាទេ (រវាងទឹកឃ្មុំថ្មី និងទឹកឃ្មុំចាស់ ទឹកឃ្មុំមកពីប្រភពផ្កាផ្សេងៗគ្នា និងទឹកឃ្មុំដែលមានកម្រិតជាតិទឹកខុសគ្នា) ។
- ប្រើប្រាស់ឧបករណ៍ដែលផលិតអំពីដែកអ៊ីណុក សំណាញ់ច្រោះដែលល្អស្អាត រឺ ស្បៃដែលមាន៤ស្រទាប់ជាជីឡាវសម្រាប់ច្រោះទឹកឃ្មុំ (បើសិនជាមិនមានសំណាញ់សម្រាប់ច្រោះ) នៅពេលកែច្នៃ ។



- ត្រូវច្រោះទឹកឃ្មុំនៅក្នុងធុងដែលស្ងួត ស្អាត ហើយផលិតពីដែកអ៊ីណុក ។ ត្រូវយកពពុះទឹកឃ្មុំចេញក្នុងរយៈពេល ៤៨ ម៉ោងបន្ទាប់ពីច្រោះ ។
- ការកាត់បន្ថយជាតិទឹកត្រូវធ្វើតាមរយៈការប្រើប្រាស់សំភារៈរឺឧបករណ៍បន្ថែមមួយចំនួនដូចជា កង្ហារ ម៉ាស៊ីនសម្ងួតជាតិទឹក និងម៉ាស៊ីនត្រជាក់នៅក្នុងបន្ទប់

ស្ងួត ស្អាត បិទជិត (៣ម x៤ម) ជាមួយផ្ទើបញ្ឈរ និងថាស ។ ទឹកឃ្មុំត្រូវដាក់នៅក្នុងថាសរយៈពេលពី ២៤-២៨ ម៉ោង ដើម្បីកាត់បន្ថយជាតិទឹក និងពពុះ ។ មិនត្រូវយកទឹកឃ្មុំទៅកំដៅ រឺស្ងោរ និងប្រើបច្ចេកទេសផ្សេងៗនោះទេ ព្រោះវាធ្វើឱ្យមានការផ្លាស់ប្តូរនូវលក្ខណៈ និងរសជាតិធម្មជាតិរបស់វា ។

- ត្រូវកត់ត្រាភាគរយនៃកម្រិតជាតិទឹកដែលបានកាត់បន្ថយ និងថ្ងៃខែកែច្នៃនៅលើធុងដាក់ទឹកឃ្មុំ ។

**ការវេចខ្ចប់:**



- អង្កេតមើលអនាម័យឱ្យបានសមរម្យពេលវេចខ្ចប់ទឹកឃ្មុំ ។ ត្រូវពាក់ស្រោមដៃ និងម៉ាស
- ត្រូវចាក់ទឹកឃ្មុំចូលដប រឺកំប៉ុងសន្សឹមៗដើម្បីជៀសវាងកើតមានពពុះ និងហៀរទឹកឃ្មុំចេញក្រៅដប
- រក្សាទឹកឃ្មុំកុំឱ្យមានពពុះមុនពេលបិទគំរបដប រឺកំប៉ុង



- ការវេចខ្ចប់ត្រូវតែធ្វើនៅក្នុងបន្ទប់ដែលស្អាតហើយស្ងួត ។ ជៀសវាងការវេចខ្ចប់នៅពេលមានភ្លៀងធ្លាក់ ។
- ត្រូវវេចខ្ចប់នៅក្នុងកំប៉ុង និងដបដែលអាចដាក់ចំណីអាហារបាន ។ បើសិនជាវេចខ្ចប់នៅក្នុងឆ្នាំង រឺក្រឡដែលធ្វើអំពីដីត្រូវតែយកក្រមួនឃ្មុំទៅបិទពាស់ពីខាងក្នុង ។



- ទឹកឃ្មុំដែលវេចខ្ចប់ហើយត្រូវតែបិទគម្រប និងបិទស្លាកសញ្ញាដោយមានភ្ជាប់នូវពត៌មានមួយចំនួនដូចជាកាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ ម្ចាស់ទឹកឃ្មុំ និងប្រភពទឹកឃ្មុំ សារធាតុចិញ្ចឹម និងទំងន់ រឺចំណុះ ។

**ការស្តុកទុក:**

- ត្រូវរក្សាទុកទឹកឃ្មុំនៅក្នុងបន្ទប់ដែលមានសីតុណ្ហភាពក្រោម ៣០ អង្សាសេ
- ត្រូវរក្សាទឹកឃ្មុំឱ្យខ្ពស់ផុតពីដី ដើម្បីជៀសវាងសំណើម
- ជៀសវាងកុំឱ្យទឹកឃ្មុំប៉ះនឹងពន្លឺថ្ងៃ ដើម្បីការពារការឆ្លងមេរោគ
- រក្សាទុកទឹកឃ្មុំនៅក្នុងធុង រឺកានស្អាតដែលមានបិទស្លាកសញ្ញាត្រឹមត្រូវ ។







book2:Layout 1 11/11/2010 4:04 PM Page 20

# ការកែច្នៃទឹកឃ្មុំរបស់សហគមន៍ដោយមាន ការត្រួតពិនិត្យគុណភាព និងអនាម័យ





book2:Layout 1 11/11/2010 4:53 PM Page 21



# ៣. ការកសាងសមត្ថភាព និងទំនាក់ទំនង



ការគ្រប់គ្រងព្រៃឈើ និងគុណភាពទឹកឃ្មុំដោយមានការទទួលខុសត្រូវ និងនិរន្តរភាពត្រូវតែមានការអង្កេតយ៉ាងតឹងរឹង ។ ដើម្បីអាចធ្វើបែបនេះបានត្រូវតែធ្វើការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់សមាជិកទាំងអស់របស់សហព័ន្ធ ។

ការប្រមូល និងការគ្រប់គ្រងទឹកឃ្មុំត្រូវគ្រប់គ្រងដោយរចនាសម្ព័ន្ធក្រុមមួយដែលមានការបែងចែកតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ។ លើសពីនេះទៀត ត្រូវតែមានប្រព័ន្ធត្រួតពិនិត្យមួយ ដើម្បីធានាឱ្យបាននូវគណនេយ្យភាព និងការគ្រប់គ្រងប្រកបដោយគុណភាពខ្ពស់ ។ នីតិវិធី និងប្រព័ន្ធរៀបចំឯកសារត្រូវតែមានចែងអំពីរចនាសម្ព័ន្ធសកម្មភាព និងដំណើរការរបស់ក្រុម ។



## ប្រព័ន្ធបែបនេះត្រូវរួមបញ្ចូលនូវ :

- រៀបចំរបាយការណ៍ឱ្យបានទៀងទាត់ (រៀងរាល់ ៦ ខែម្តង)
- ប្រជុំឱ្យបានទៀងទាត់
- រៀបចំគណនេយ្យនៅធនាគារឱ្យសហគមន៍
- រក្សាទុកនូវឯកសារមួយចំនួន (បញ្ជីឈ្មោះសមាជិកក្រុម លក្ខន្តិកៈ ការកត់ត្រាពីការប្រមូលទឹកឃ្មុំ និងប្រគល់ទឹកឃ្មុំ និងការកត់ត្រាហិរញ្ញវត្ថុជាដើម)



រាល់ឯកសារទាំងឡាយត្រូវតែកត់ត្រាឱ្យបានសមរម្យ ហើយអាចប្រើប្រាស់បានសម្រាប់ការត្រួតពិនិត្យនៅក្រោមនីតិវិធី និងច្បាប់ប្រតិបត្តិការរបស់សហព័ន្ធ ។

រាល់សកម្មភាពទាំងអស់ត្រូវតែអនុវត្តទៅតាមច្បាប់ និងតំរូវការរបស់រដ្ឋាភិបាលដែលមានស្រាប់ ។ ត្រូវមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន និងភ្នាក់ងាររដ្ឋាភិបាលនូវរាល់ការអនុវត្តសកម្មភាពទាំងអស់ ដើម្បីទទួលបានការគាំទ្រពីពួកគេ ។

# ដំណើរការទីផ្សារទឹកឃ្មុំ



book2:Layout 1 11/11/2010 4:57 PM Page 23



# ៤. ការបែងចែកផលប្រយោជន៍

- រាល់សកម្មភាពទាំងអស់ក្នុងការប្រមូលទឹកឃ្មុំ ការគ្រប់គ្រង និងទីផ្សារត្រូវផ្តល់អត្ថប្រយោជន៍ដល់សមាជិកស្របច្បាប់របស់សហព័ន្ធ ។
- ការងារត្រូវបានបង្កើតឱ្យសហគមន៍ចេញពីសហគ្រាសទឹកឃ្មុំ ដែលកត្តាទាំងនេះអាចជួយពង្រឹងដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។
- គោរព និងលើកកម្ពស់ប្រពៃណី និងជីវភាពរស់នៅក្នុងមូលដ្ឋានដូចជា ការប្រមូលទឹកឃ្មុំ និងអនុផលព្រៃឈើផ្សេងៗទៀត
- ការងារគ្រប់គ្រងត្រូវតែមានធនធានគ្រប់គ្រាន់ និងមានសំណងត្រឡប់មកវិញ
- ការបែងចែកផលប្រយោជន៍ក្នុងចំណោមសមាជិកក្រុមត្រូវតែរៀបចំ និងប្រកាន់ភ្ជាប់នូវការចូលរួម ។



## សហព័ន្ធសហគ្រាសអភិរក្សឃ្មុំព្រៃកម្ពុជា

| ឈ្មោះក្រុមឃ្មុំ | ទីតាំង | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដីសហគមន៍ | ចំនួនសមាជិកឆ្នាំ២០១០ | ឈ្មោះអ្នកទំនាក់ទំនង |
|---|---|---|---|---|---|
| ១-ក្រុមអ្នកប្រមូលឃ្មុំ សហគមន៍ភ្នំទ័ពជាង | ភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង | សហគមន៍ព្រៃឈើភ្នំទ័ពជាង | ៣០៣៤ ហត | ៧៩ នាក់ | ម៉ឹង មាន |
| ២-ក្រុមអ្នកប្រមូលឃ្មុំ ភូមិប្រលាន | ភូមិប្រលាន ឃុំកណ្តោល ស្រុកបូទុមសាគរ ខេត្តកោះកុង | សហគមន៍តំបន់ការពារ ឃុំកណ្តោល | ១៤៤០ ហត | ៤២ នាក់ | សារាយ រឿន |
| ៣-ក្រុមអ្នកប្រមូលឃ្មុំ ភូមិព្រាំង | ភូមិព្រាំង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង | សហគមន៍តំបន់ការពារព្រាំង ចំការ និងក្រោម | ៨៥៩ ហត | ៦៤ នាក់ | យៀន មេន |
| ៤-ក្រុមអ្នកប្រមូលឃ្មុំ ភូមិតានី | ភូមិតានី ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង | សហគមន៍តំបន់ការពារជីខលើ | ៩៥០ ហត | ៥៣ នាក់ | លី តៃ |
| ៥-ក្រុមអ្នកប្រមូលឃ្មុំ ភូមិនេសាទ | ភូមិនេសាទ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង | សហគមន៍នេសាទជ្រោយស្វាយ | ២២៩២៤ ហត | ១៧ នាក់ | ផន ឃិន |
| ៦-សមាគមអ្នកប្រមូលទឹកឃ្មុំជនជាតិដើមឃុំក្រង់តេះ | ភូមិក្រង់តេះ ឃុំក្រង់តេះ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី | សហគមន៍ព្រៃការពារក្រង់រតួន | ៧៩៤៦៧ ហត | ២១ នាក់ | ម៉ន ចន្ទី |
| ៧-សមាគមអ្នកប្រមូលទឹកឃ្មុំ ជនជាតិដើមឃុំពូជ្រៃ | ភូមិពូជ្រៃ ឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី | សហគមន៍ព្រៃការពារត្រពាំងភ្លើម | ៤៩៩៣៣ ហត | ៤៩ នាក់ | ម្យ៉ាង ពួន |
| ៨-ក្រុមអ្នកប្រមូលឃ្មុំ ភូមិមិលដួង និងឃ្សឹម | ភូមិឃ្សឹម ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ | សហគមន៍ការពារធនធានធម្មជាតិ ៣ភូមិ | ២៤៥៩ ហត | ៤៥ នាក់ | គុជ គាន |
| ៩-ក្រុមអ្នកប្រមូលឃ្មុំ ភូមិវាលកន្សែង | ភូមិវាលកន្សែង ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ | សហគមន៍ព្រៃឈើ ភូមិវាលកន្សែង | ១៧៥២.៨៧ ហត | ៣៣ នាក់ | តេង រ៉ន |
| ១០-ក្រុមអ្នកប្រមូលឃ្មុំ សហគមន៍ជនជាតិដើម ភាគតិចកួយ ភូមិក្រាំងដូង | ភូមិក្រាំងដូង ឃុំក្រាំងដូង ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ | សហគមន៍ជនជាតិដើមភាគតិចកួយ ភូមិក្រាំងដូង | | ២០ នាក់ | អ៊ិត វុន |
| ១១-ក្រុមអ្នកប្រមូលឃ្មុំ សហគមន៍ជនជាតិដើមភាគតិចកួយ ភូមិអន្លង់ស្វាយ | ភូមិអន្លង់ស្វាយ ឃុំក្រាំងដូង ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ | សហគមន៍ជនជាតិដើមភាគតិចកួយ ភូមិអន្លង់ស្វាយ | | ២០ នាក់ | ឈឿង ឆ្នៃ |
| ១២-ក្រុមអ្នកប្រមូលឃ្មុំ សហគមន៍ជនជាតិដើមភាគតិចកួយ ភូមិពើក | ភូមិពើក ឃុំពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ | សហគមន៍ជនជាតិដើមភាគតិចកួយ ភូមិពើក | | ២២ នាក់ | ញៀន កាន |
| ១៣-ក្រុមអ្នកប្រមូលឃ្មុំ សហគមន៍ជនជាតិដើមភាគតិចកួយ ភូមិក្រឡាពាស | ភូមិក្រឡាពាស ឃុំព្រីងធំ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ | សហគមន៍ជនជាតិដើមភាគតិចកួយ ភូមិក្រឡាពាស | | ២៨ នាក់ | ឡាំ សោម |
| ១៤-សហគ្រាសខ្នាតតូចស្រែឬស្សី | ភូមិស្រែឬស្សី ឃុំស្រែឬស្សី ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង | សហគមន៍ព្រៃឈើ ភ្នំរាជសី | ១៩៥៨ ហត | ៣៦ នាក់ | អ៊ី ចន្ទ័តារា |
| ១៥-ក្រុមកែច្នៃទឹកឃ្មុំ ធម្មជាតិស្ត្រីបូរីអូស្វាយ | ភូមិអូស្វាយ ឃុំអូស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង | សហគមន៍ព្រៃឈើបូរីអូស្វាយ | ៤៣៨៣ ហត | ២៩ នាក់ | គង់ វុទ្ធី |
| ១៦-ក្រុមអ្នកប្រមូលឃ្មុំ ឃុំចាអ៊ុង | ភូមិចាអ៊ុង ឃុំចាអ៊ុង ស្រុកអូជុំ ខេត្តរតនគិរី | សហគមន៍ព្រៃឈើឃុំចាអ៊ុង | ២៩៥៥ ហត | ៣១ នាក់ | ទ្រិ ងួត |

book2:Layout 1 11/11/2010 5:45 PM Page 25

## សហព័ន្ធសហគ្រាសប្រមូល និងអភិរក្សឃ្មុំព្រៃកម្ពុជា

សូមថ្លែងអំណរគុណដល់អង្គការដៃគូដែលបានជួយគាំទ្រការសម្របសម្រួលបច្ចេកទេសរួមមានៈ

អង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អនុផលព្រៃឈើ ( NTFP-EP)

ក្រុមការងារអនុផលព្រៃឈើកម្ពុជា (CNWG)

អង្គការមូលនិធិដើម្បីអភិរក្សធម្មជាតិកម្ពុជា (WWF Cambodia)

អង្គការផេកកម្ពុជា (PACT Cambodia)

អង្គការអភិវឌ្ឍន៍សហគមន៍កម្ពុជា (CCD)

អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED)

អង្គការសេដាក (CEDAC)

Fundacion ETEA

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជនបទកម្ពុជា (CIRD)

អង្គការពន្លកខ្មែរ (Ponlok Khmer)

អង្គការអ៊ុកស្វាមអង់គ្លេស (Oxfam GB)

អង្គការសមាគមន៍ថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA)

អង្គការម្លប់ព្រហ្មវិហារធម៌ (PVT)

book2:Layout 1 11/11/2010 5:45 PM Page 26

## ឃ្មុំព្រៃកម្ពុជាមានលក់នៅ

- ហាង Naturewild ផ្ទះលេខ ១០ ផ្លូវលេខ៤២០ សង្កាត់បឹងត្របែក ភ្នំពេញ
- ផ្សារកសិផលធម្មជាតិ របស់សហគ្រាសសេដាក
  - សាខាទី១: ផ្ទះលេខ ៦៨៩ បេ វិថីកម្ពុជាក្រោម សង្កាត់ទឹកល្អក់១ ខ័ណ្ឌភ្នំពេញ
  - សាខាទី២: ផ្ទះលេខ ១៣ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង៣ ខ័ណ្ឌចំការមន ភ្នំពេញ
  - សាខាទី៣: ផ្ទះលេខ ៦៧ ផ្លូវ ២៣០ សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក ភ្នំពេញ
  - សាខាទី៥: ផ្ទះលេខ ២០ ផ្លូវ ៣៦ សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ ភ្នំពេញ
  - សាខាទី៦: ផ្ទះលេខ ១៩១ ផ្លូវ ៥៩២ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ភ្នំពេញ
  - សាខាទី៧: ផ្ទះលេខ ៥៥ ផ្លូវ ១៣ សង្កាត់ផ្សារចាស់ ខ័ណ្ឌដូនពេញ ភ្នំពេញ
  - សាខាទី៨: ផ្ទះលេខ ២២០ ផ្លូវ ៦៣ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ភ្នំពេញ
- ផ្សារទំនើប:
  - ឡាក់គីផ្លូវព្រះស៊ីហនុ ភ្នំពេញ
  - ឡាក់គីសូរិយា ភ្នំពេញ
  - ឡាក់គីសុវណ្ណា ភ្នំពេញ
  - ឡាក់គីស៊ីធីម៉ល ភ្នំពេញ
  - ឡាក់គីម៉ល សៀមរាប
  - ផ្សារទំនើបបាយ័ន ភ្នំពេញ
  - អារ៉ូណាម៉ាត ផ្ទះ ៧៧០ ផ្លូវកម្ពុជាក្រោម ភ្នំពេញ